# ផ្សារភ្ជាប់ជាមួយរដ្ឋបាលមូលដ្ឋាន ដើម្បីបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាលនៅកម្ពុជា

នៅដើមសតវត្សទី ២១ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់គោលដៅជាក់លាក់មួយ ដើម្បីសម្រេចឲ្យបាននូវការគ្របដណ្តប់អនាម័យទូទាំងប្រទេសនៅឆ្នាំ ២០២៥ ។ ក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ការខិតខំប្រឹងប្រែងកាន់តែមានការកើនឡើង ដើម្បីសំរេចជោគជ័យនូវគោលដៅនេះ តាមរយៈការធ្វើផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងការលើកកម្ពស់ អនាម័យនៅជនបទ ដែលបានអនុម័ត ដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅដើមឆ្នាំ ២០១៤ ។

លោក ជ្រាយ ប៉ុម ប្រធាននាយកដ្ឋានថែទាំសុខភាពជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាស្ថាប័នរបស់រាជរដ្ឋាភិបាលទទួលខុសត្រូវលើកិច្ចការអនាម័យជនបទបានមានប្រសាសន៍ថា "ជាមួយនឹងកិច្ចសហការនិងការសម្របសម្រួលនាពេលបច្ចុប្បន្ន ជាមួយដៃគូអភិវឌ្ឍន៍នៃវិស័យនេះ ខ្ញុំមានជំនឿថា យើងនឹងអាចឈានដល់គោលដៅឆ្នាំ ២០២៥ នេះជាមិនខាន" ។

កម្មវិធីទឹកស្អាតនិងអនាម័យ (WSP) នៃក្រុមប្រតិបត្តិការសកល វិស័យទឹក (Water Global Practice) របស់ធនាគារពិភពលោក កំពុងចូលរួមគាំទ្រ រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាអនាម័យជូនប្រជាជនជាទ្រង់ទ្រាយធំប្រកបដោយនិរន្តរភាព និងកំពុងផ្តល់យោបល់ដល់រដ្ឋាភិបាលថ្នាក់ជាតិអំពីផែនការអនុវត្តការផ្តល់សេវាអនាម័យតាមបែបវិជ្ជមានការ ដើម្បីឲ្យរដ្ឋបាលថ្នាក់ស្រុកនិងឃុំ ទទួលយកអណត្តិសម្រាប់អនុវត្តកម្មវិធីអនាម័យ នេះ ។

សមត្ថភាពមន្ត្រីថ្នាក់ស្រុកនិងឃុំនៅមូលដ្ឋានគឺជាគន្លឹះនៃភាពជោគជ័យក្នុងការលើកកម្ពស់អនាម័យ ព្រោះអាចធ្វើឱ្យអ្នកដែលនៅជិតបញ្ហានិងយល់ដឹងពីបរិបទមូលដ្ឋានជាងគេ អាចប្រមែប្រមូលប្រជាពលរដ្ឋ និងវិស័យឯកជននៅមូលដ្ឋាន ដើម្បីស្វែងរកដំណោះស្រាយនានា ។ "រដ្ឋបាលមូលដ្ឋានកំពុងតែចូលរួមធនធាន ដែលរួមមានទាំងហិរញ្ញប្បទានផងក្នុងការផ្តល់សេវាអនាម័យជនបទ" លោក ចាន់ វីរៈ អ្នកឯកទេសផ្នែកទឹកស្អាតនិងអនាម័យនៃកម្មវិធីទឹកស្អាតនិងអនាម័យរបស់ធនាគារពិភពលោក (WSP) បានពន្យល់ថា "បច្ចុប្បន្ន ឃុំខ្លះបានបែងចែកថវិការបស់ខ្លួនមួយផ្នែកសំរាប់ការងារអនាម័យ ដែលជាជំហានដ៏ធំមួយ ឆ្ពោះទៅកាន់ការសំរេចដោយជោគជ័យនូវការទទួលបានអនាម័យទូទាំងប្រទេស" ។

ស្រុកនិងឃុំកំពុងធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងដៃគូផ្សេងទៀត ក្នុងការផ្សារភ្ជាប់ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) ដើម្បីជួយផ្តល់ ប្រាក់កម្ចីខ្នាតតូចដល់គ្រួសារក្រីក្រដែលមានការខ្វះខាតប្រាក់កាស ក្នុងការទិញបង្គន់អនាម័យ ។ គម្រោងហិរញ្ញប្បទានសាកល្បងដែលមានរយៈពេល ៩ ខែសម្រាប់ អនាម័យជនបទនៅខេត្តកណ្តាល អាចឲ្យគ្រួសារចំនួន ១៩៩៤ អាចទិញបង្គន់អនាម័យដោយបង់រំលោះ ដែលនេះ ជា ភស្តុតាងថា ការទទួលបានហិរញ្ញប្បទានអាចពន្លឿនការទទួលបានបង្គន់អនាម័យប្រសើរជាងមុនសំរាប់គ្រួសារនានា ដោយរួមមានទាំងគ្រួសារក្រីក្រផងដែរ ។ ការទទួលបានប្រាក់កម្ចីរបស់គ្រួសារដែលខ្វះខាតថវិកាគឺមានសារៈសំខាន់សំរាប់ធានាថាពួកគាត់មានឱកាសទិញបង្គន់អនាម័យ ។ ទោះជាយ៉ាងណា គ្រួសារ ក្រីក្របំផុតដែល រកប្រាក់ចំណូលបានតិចជាង

១,២៥ ដុល្លារអាមេរិកក្នុងមួយថ្ងៃ នៅតែមិនអាចទទួលបានប្រាក់កម្ចីដដែល ដោយសារពួកគាត់ត្រូវបានសន្មត់ថា មិនមានលទ្ធភាពសង ត្រឡប់វិញបាន ។

បន្ថែមលើការផ្តល់ហិរញ្ញប្បទាន គំនិតឆ្នៃប្រឌិតថ្មីៗក្នុងការបង្កើតគំរូបង្គន់ ការផលិត និងការផ្គត់ផ្គង់ផលិតផលបង្គន់ បានជួយឱ្យផលិតផលបង្គន់មានតម្លៃទាប ដែលបានជួយប្រជាជនកាន់តែមានលទ្ធភាពទទួលបានអនាម័យគ្រប់ៗគ្នា។ គេបានឃើញកិច្ចការនេះរួចទៅហើយនៅប្រទេសកម្ពុជាតាមរយៈគម្រោងបង្កើតបង្គន់ងាយស្រួល (Easy Latrine) ដែលជាបង្គន់អនាម័យចាក់ទឹកមានតម្លៃថោកដែលអាចឱ្យប្រជាពលរដ្ឋទិញបាន ហើយការអភិវឌ្ឍន៍និងការបង្កើតទីផ្សារថ្មីរបស់គម្រោងនេះទទួលបានការគាំទ្រពីធនាគារពិភពលោក ។ ក្នុងរយៈពេលត្រឹមតែ ៤ ឆ្នាំប៉ុណ្ណោះ តាំងពីការចាប់ផ្តើមគម្រោងនេះមក បង្គន់អនាម័យប្រភេទនេះចំនួនប្រមាណ ១៧០០០០ ត្រូវបានលក់ចេញដោយសហគ្រិននៅថ្នាក់មូលដ្ឋាន ដែលការនេះបង្ហាញថា សហគ្រាសមូលដ្ឋានអាចរកប្រាក់ចំណេញបានពីការផលិតនិងការលក់បង្គន់អនាម័យដែលមានតម្លៃថោក និងអាចឱ្យប្រជាពលរដ្ឋមួយចំនួនធំដែលមានប្រាក់ចំណូលតិចតួចមានលទ្ធភាពទិញ ។ នេះជាឧទាហរណ៍ មួយដែលបង្ហាញថាការរាប់បញ្ចូលនូវបរិបទមូលដ្ឋាន តម្រូវការរបស់អ្នកទិញ និងលទ្ធភាពទិញបានរបស់ប្រជាពលរដ្ឋ ជាកត្តាសំខាន់ក្នុងការជួយឱ្យប្រទេសនានា ដូចជាប្រទេសកម្ពុជាជាដើម សំរេចបានដោយជោគជ័យនូវគោលដៅនៃការទទួលបានអនាម័យទូទាំងប្រទេស ។

*ក្នុងពេលថ្មីៗនេះ អ្នកស្រី មៅ សុគន្ធា ដែលជាប្រជាជន ក្នុងភូមិថ្មី ខេត្តកណ្តាល ប្រទេសកម្ពុជា បានសង់បង្គន់អនាម័យចាក់ទឹកមួយនៅក្រៅផ្ទះ ដែលកូនប្រុស និងកូនស្រីគាត់ជាអ្នកចេញលុយ តាមរយៈការបង់ប្រាក់រំលោះប្រចាំខែចំនួន ២៥ ដុល្លារអាមេរិក ក្នុង១ខែ។*

«ជាមួយនឹងកិច្ចសហការនិងការសម្របសម្រួលនាពេលបច្ចុប្បន្ន ជាមួយដៃគូអភិវឌ្ឍន៍នៃវិស័យនេះ ខ្ញុំមានជំនឿថា យើងនឹងអាចឈានដល់គោលដៅឆ្នាំ ២០២៥ នេះជាមិនខាន»

លោក ជ្រាយ ប៉ុម ប្រធាននាយកដ្ឋានថែទាំសុខភាព ជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការសំរេចនូវការគ្របដណ្តប់អនាម័យទូទាំងប្រទេសនៅឆ្នាំ ២០២៥

លោកស្រី សាន សុផាន ដែលជាអ្នកសម្របសម្រួល អនាម័យឃុំ និងជាសមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រីនិងកុមារ បាន សួរអ្នកចូលរួមក្នុងការប្រជុំផ្សព្វផ្សាយចំណេះដឹងអំពីអនាម័យថា៖ "តើអ្នកណាខ្លះមានបង្គន់អនាម័យនៅផ្ទះ?" មានតែអ្នកភូមិដែលអង្គុយមុខគាត់ប្រមាណមួយភាគបួនប៉ុណ្ណោះបានលើកដៃឡើង ។

លោកស្រី សុផានកំពុងសម្របសម្រួលការប្រជុំស្តីពីការយល់ដឹងផ្នែកអនាម័យនៅភូមិថ្មី ដែលជាភូមិតូចមួយនៅជនបទមានប្រជាជនចំនួន ១៩៦ គ្រួសារ ក្នុងខេត្តកណ្តាលនៃប្រទេសកម្ពុជា ដែលជាប្រទេសមានអត្រានៃការបន្ទោ

របង់ពាសវាលពាសកាលខ្ពស់ជាងគេបំផុតនៅអាស៊ីបូព៌ា ក្នុងអត្រាចំនួន ៥១% ។ ការប្រជុំនេះផ្តោតលើ ការប៉ះពាល់របស់បង្គន់អនាម័យលើសេចក្តីថ្លៃថ្នូរ ភាពងាយស្រួល និងសុវត្ថិភាព ក្នុងគោលដៅបង្កើនចំនួនគ្រួសារដែលប្រើប្រាស់បង្គន់អនាម័យនោះ។

ក្នុងចំណោមអ្នកចូលរួមការប្រជុំនោះ អ្នកស្រី សរ មិច មិនបានលើកដៃ ឡើយ ។ គាត់គ្មានបង្គន់អនាម័យនៅផ្ទះទេ មានន័យថា គាត់ ស្វាមីគាត់ កូនគាត់ និងចៅទាំងបីរបស់គាត់ត្រូវដើរទៅ វាលស្រែជិតៗនោះ ដើម្បីបន្ទោរបង់។ អ្នកស្រី សរ មិចយល់ដឹងយ៉ាងច្បាស់ពីផលប៉ះពាល់អវិជ្ជមាននៃការបន្ទោរបង់ពាសវាលពាសកាល មកលើសុខភាពគ្រួសារគាត់ ព្រោះគាត់ក៏បានអនុវត្តសកម្មភាពអនាម័យផ្សេងទៀត ដូចជាការផឹកទឹកដាំពុះនិងការលាងសំអាតដៃជាដើមផងដែរ ។ គាត់ចង់បានបង្គន់អនាម័យមួយ តាំងពីគាត់បានចូលរួមប្រជុំស្រដៀងគ្នានេះកាលពីខែមុនម្ល៉េះ គ្រាន់តែគាត់ និងគ្រួសារគ្មានលទ្ធភាពទិញតែប៉ុណ្ណោះ ។

ប៉ុន្តែ នៅក្នុងកិច្ចប្រជុំលើកនេះ លោកស្រី សុផានដែលបានទទួលការបណ្តុះបណ្តាលតាមរយៈកម្មវិធីទឹកស្អាត និងអនាម័យរបស់ធនាគារពិភពលោក (WSP) បានសហការជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅមូលដ្ឋាន ដើម្បីផ្តល់ប្រាក់កម្ចីខ្នាតតូចដល់ប្រជាពលរដ្ឋក្នុងភូមិ ដែលមានបំណងចង់ទិញបង្គន់អនាម័យ ។ នៅក្នុង ប្រជុំលើកនេះ អ្នកស្រី សរ មិច ទទួលបានប្រាក់កម្ចីចំនួន ៥០ដុល្លារអាមេរិក ដែលអាចឱ្យគាត់ទិញចានបង្គន់អនាម័យចាក់ទឹកនិងទម្រផ្នែកក្រោម ។ បង្គន់អនាម័យនេះនឹងជួយអ្នកស្រី សរ មិច និងក្រុមគ្រួសារ បញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល ជួយកាត់បន្ថយការគំរាមកំហែងផ្នែកសុខភាព ដូចជាជម្ងឺរាក ដែលបង្កឡើងពីការចម្លងមេរោគពីការបន្ទោរបង់ពាសវាលពាសកាល ។ គាត់កំពុងមានគម្រោងសន្សំប្រាក់សំរាប់សាងសង់ជញ្ជាំងដែលជាប់ជុំវិញបង្គន់អនាម័យ ប៉ុន្តែឥឡូវនេះ គាត់និងក្រុមគ្រួសារយកភួយចាស់មករុំសិន ដើម្បីបិទបាំង ។

នៅប្រទេសកម្ពុជា មានប្រជាជនជាងពាក់កណ្តាលនៃចំនួនប្រជាជនសរុប ខ្វះលទ្ធភាពទទួលបានអនាម័យល្អប្រសើរ។ នៅតំបន់ជនបទ ស្ថានភាពនេះរឹតតែអាក្រក់ថែមទៀត ដោយ ៨៦% នៃ ប្រជាជនក្រីក្រជាងគេនៅជនបទនៅតែបន្ទោរបង់ពាសវាលពាសកាលនៅឡើយ ។ កង្វះខាតនៃការទទួលបានអនាម័យបានដាក់បន្ទុកផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ចយ៉ាងធ្ងន់ធ្ងរលើប្រជាពលរដ្ឋកម្ពុជានៅជនបទ ដែលមានតាំងពីអត្រាមរណភាពកុមារដោយសារជម្ងឺរាកក្នុងកំរិតខ្ពស់ រហូតដល់ការរារាំងការរីកធំធាត់របស់កុមារ (បង្កឲ្យកុមារក្រិន) និងការអភិវឌ្ឍន៍របស់កុមារយឺតថែមទៀតផង ។